# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ១០:០០ នាទីព្រឹកនៅ ក្រុមហ៊ុន យីង ហ៊ី (ខេមបូឌា) ហ្គាមេន ខូ អិល ធីឌី បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោក XIA NENGBIAO ជានាយកក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុ គ្មានអ្នកបញ្ជាទិញ។

សមាសភាពចូលរួមប្រជុំមានៈ

1- ភាគីតំណាងរោងចក្រ

- លោក XIA NENGBIAO ជានាយករោងចក្រ
- លោក ចាន់ លីឌី ជារដ្ឋបាល
- លោក ស្រី គៀត សាវត្តី ជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោក លឹម វ៉ាត ជាតំណាងកម្មករ
- លោក គង់ ចាន់រី ជាតំណាងកម្មករ
- លោក គឹន លីន ជាតំណាងកម្មករ
- លោក ស្រី ម៉ៅ សារីន ជាតំណាងកម្មករ

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៥២២នាក់ ក្នុងរយៈពេល៦០ថ្ងៃ ដែលចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុននឹងផ្តល់នូវ ប្រាក់លើកទឹកចិត្តចំនួន៣០ដុល្លា ប្រាក់ព្រីន ៥ ដុល្លា- ថ្លៃធ្វើដំណើរ៥ ដុល្លា - សរុប ផ្តល់ជូន ៤០ ដុល្លា ក្នុង១ខែ សំរាប់កម្មករម្នាក់ៗ ហើយក្រុមហ៊ុននឹងគោរព ទៅតាមប្រកាសរបស់ក្រសួងការងារនៃព្រះរាជាណាចក្រកម្ពុជា។

3- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

4- ប្រសិនបើក្រុមហ៊ុនមានវត្ថុធាតុដើមចូលមកវិញ ក្រុមហ៊ុននឹងហៅបងប្អូនកម្មករនិយោជិតមកធ្វើការជាធម្មតា។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១០:៤៥ នាទីព្រឹក នាថ្ងៃទីទី ២០ ខែ តុលា ឆ្នាំ ២០២២ ដ៏ដែលក្រោមបរិយាកាសរីករាយ។

ភ្នំពេញ ថ្ងៃទី ...២០... ខែ ...តុលា... ឆ្នាំ...២០២២

| | |
|---|---|
| បានឃើញនឹងឯកភាព | បានឃើញនឹងឯកភាព |
| តំណាងកម្មករ | នាយកក្រុមហ៊ុន |

លោក លឹម វ៉ាត

លោក គង់ ចាន់រី

XIA NENGBIAO

លោកស្រី ម៉ៅ សារីន

លោក គឹន លីន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុនៈ យីង ហ៊ី (ខេមបូឌា) ហ្គាមេន ខូ អិល ធីឌី**
លេខបញ្ជីពាណិជ្ជកម្មៈ ០០០០៣២៣០
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.ៈ ១០០៥៧៦២៥
លេខគណនីធនាគារៈ ០០២៣៧២៩៥៥
អាសយដ្ឋានៈ លេខផ្ទះ៤០៤ លេខផ្លូវ៣៨ ភូមិ ទ្រា១ ឃុំ/សង្កាត់ ស្ទឹងមានជ័យទី១
ក្រុង/ស្រុក/ខណ្ឌ មានជ័យ រាជធានី/ខេត្ត ភ្នំពេញ
ទូរស័ព្ទលេខៈ ០៨៩៨៦៦៨៥៥ អ៊ីមែល (E-mail)ៈ lydychan8@gmail.com

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ៥២២ នាក់ រយៈពេល ៦០ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំគ្មានការបញ្ជាទិញ
ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៥២២ នាក់ (ស្រី ៤២៣ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥២២ នាក់ រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ
ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន៣០ដុល្លា ប្រាក់ព្រីន ៥ ដុល្លា- ថ្លៃធ្វើដំណើរ៥ ដុល្លា - សរុប ផ្តល់ជូន ៤០ ដុល្លា ក្នុង១ខែ សំរាប់កម្មកម្នាក់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២២
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យីង ហ៊ី (ខេមបូឌា) ហ្គាមេន YING HE (CAMBODIA) GARMENT CO.,LTD. KINGDOM OF CAMBODIA

XIA NENGBIAO

**សូមភ្ជាប់មកជាមួយ:**
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)